គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
លេខ ៤៨ ចេញផ្សាយថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២
No. 48 Released on June 13, 2022
និយ័តករបរធនបាលកិច្ច
Trust Regulator
អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការបំពេញលក្ខខណ្ឌដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនបរធនបាល

## Eligibility for Qualification Recognition in Trustee Company




រូបភាព | Picture: http://www.managingamericans.com/pub/images/20120910205730_BuildingTrustWithCoWorkers.jpg

យោងតាមច្បាប់ស្តីពី "បរធនបាលកិច្ច" (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ អភិបាល នាយកប្រតិបត្តិ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធន ត្រូវដាក់ពាក្យស្នើសុំមក **ន.ប.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ប.ធ.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២. ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣. មានសញ្ញាបត្រ និងបទពិសោធន៍ការងារ ដូចខាងក្រោម÷

ក. អភិបាល និងនាយកប្រតិបត្តិ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀត ដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៥(ប្រាំ) ឆ្នាំក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ។

ខ. ប្រធានប្រតិបត្តិការ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀត ដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៣(បី) ឆ្នាំ ក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ។

គ. បុគ្គលិកជំនាញផ្នែកច្បាប់ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ៣(បី)ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

ឃ. គណនេយ្យករជំនាញបរធន ត្រូវបំពេញលក្ខខណ្ឌមួយចំនួនក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

-មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកគណនេយ្យ ឬផ្នែកពាក់ព័ន្ធនិងមានបទពិសោធន៍ការងារធ្វើជាគណនេយ្យករយ៉ាងតិច ៣(បី) ឆ្នាំ ក្នុងវិស័យបរធនបាលកិច្ច ឬហិរញ្ញវត្ថុ

-ជាគណនេយ្យករជំនាញ។

៤. ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនបរធនបាល។

៥. ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ប.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ប.ធ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២(ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ប.ធ** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ **ន.ប.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ប.ធ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

៦. មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈ ដូចមានចែងក្នុងចំណុច ក ដល់ ញ នៃកថាខណ្ឌទី២ នៃប្រការ១៦ នៃប្រកាសស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច”។

លក្ខខណ្ឌគុណវុឌ្ឍិដូចមានចែងនេះ មិនអនុវត្តចំពោះបរធនបាល ជាបុគ្គលសាធារណៈទាំងឡាយណាដែលតែងតាំងដោយរាជរដ្ឋាភិបាលនោះ។

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on " Rules on the Management, Organization, and the Functioning of Trust ", in order to be recognized as qualified person, Director, Chief Executive Officer, legal specialist and trust accountant must apply according to the form and provided attachments determined by the Trust Regulator and fulfill the following conditions:

1. Has good character and personality.
2. A capable person residing in Cambodia.
3. Have the following educational background and work experiences:

A. The director and Chief Executive Officer must have at least a higher education degree related to the field of Trust or finance or other degree of similar value in the field of finance and has knowledge and at least 5 years of work experience in the field of Trust or Finance.

B. Operational manager must have at least a higher education degree related to the field of Trust or finance or other degree of similar value in the field of finance and has knowledge and at least 3 years of work experience in the field of Trust or Finance.

C. Legal specialist must have at least a bachelor degree in law and at least 3 years of work experience in the financial sector.

D. Accountant specialized in Trust must meet some of the following conditions:

- Must have at least higher education in accounting or related field and at least 3 years of working experience as an accountant in the field of Trust or finance.
- A specialized accountant.

4. Provide appointed letter from the Trustee company.
5. Participate in training courses and exams organized by the Trust Regulator or by a training institution authorized by the Trust Regulator. The exam result will be valid for 2 years from the date which the exam results are announced. Applicants must continue attending education organized by the Trust Regulator or by a training institution authorized by the Trust Regulator before the exam results expire.
6. Not in the situation or circumstances as stated in point A to the point J of the second paragraph of Article 16 of this Prakas on " Rules on the Management, Organization, and the Functioning of Trust ".

These qualification conditions do not apply to any Trustee that is public person appointed by the Royal Government.

**អត្ថបទ÷ ភាន់ វីរ៉ាលីន | Article: Phorn Viralynn**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.